## ខ្លឹមសាររៀបរាប់ខាងក្រោមគឺជាវ៉ាក់សាំង (ថ្នាំចាក់) និងការពិនិត្យដែលអាចជាផ្នែកមួយនៃការទៅជួបអ្នកផ្តល់សេវារបស់កូនអ្នក។

គោលការណ៍ណែនាំទាំងអស់ដែលប្រើដោយ Molina គឺបានមកពី American Academy of Pediatrics, The Advisory Committee of Immunization Practices, The U.S. Preventive Services Task Force, និង Centers for Disease Control and Prevention។

**វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B** – ស៊េរីចាក់បីដង ដើម្បីបង្ការកុំឱ្យកុមារឆ្លងជំងឺថ្លើមធ្ងន់ធ្ងរ។ វាអាចបណ្តាលឱ្យខូចថ្លើម មហារីកថ្លើម ឬស្លាប់បាន។

**វីរុសធ្វើឱ្យកុមាររាករូស** - ស៊េរីថ្នាំចាក់ដើម្បីបង្ការកុំឱ្យកុមារតូចៗរាករូសធ្ងន់ធ្ងរ។

**ខាន់ស្លាក់ តេតាណូស ក្អកមាន់ (DTap)** - ស៊េរីថ្នាំចាក់ដើម្បីបង្ការកុំឱ្យកុមារឆ្លងជំងឺបង្កពីបាក់តេរីដែលឆ្លងរាលដាលខ្លាំងដូចជា ខាន់ស្លាក់ តេតាណូស ឬ ក្អកមាន់ (ក្អកខុងៗ)។ មុនពេលយើងមានថ្នាំចាក់ទាំងនេះ កុមារជាច្រើននាក់បានស្លាប់ដោយសារជំងឺទាំងនេះ។

**ញូម៉ូខូខល** - ស៊េរីថ្នាំចាក់ដើម្បីបង្ការកុំឱ្យកុមារដែលមានអាយុក្រោមប្រាំឆ្នាំឆ្លងជំងឺដែលបណ្តាលឱ្យមានជំងឺសួត រលាកស្រោមខួរ ជំងឺឈាម ជំងឺត្រចៀក ហើយអាចស្លាប់ទៀតផង។

**វ៉ាក់សាំងប៉ូលីយ៉ូអសកម្ម** - ស៊េរីថ្នាំចាក់ដើម្បីបង្ការកុំឱ្យកុមារឆ្លងវីរុសប៉ូលីយ៉ូ ជាជំងឺដែលអាចធ្វើឱ្យខ្វិន ឬស្លាប់បាន។

**ផ្តាសាយធំហេម៉ូហ្វីលីសប្រភេទ B** - ស៊េរីថ្នាំចាក់ដើម្បីបង្ការជំងឺដែលបង្កដោយវីរុសក្នុងខ្លួនទារក និងកុមារ។ បើគ្មានថ្នាំចាក់នេះទេ កុមារអាចវិវឌ្ឍទៅជាថ្លង់ មានជំងឺខួរក្បាល ឬស្លាប់បាន។

**ផ្តាសាយធំ** - ថ្នាំចាក់រៀងរាល់ឆ្នាំដើម្បីបង្ការកុំឱ្យកុមារអាយុ 6 ខែឡើងទៅឆ្លងជំងឺផ្តាសាយធំ។ មានផ្តល់ជូនចាប់ពីរដូវស្លឹកឈើជ្រុះរៀងរាល់ឆ្នាំ សំខាន់ខ្លាំងណាស់សម្រាប់កូនៗរបស់យើងដែលមានជំងឺហឺត និងបញ្ហាសុខភាពរ៉ាំរ៉ៃផ្សេងទៀត។

**កញ្ជ្រឹល ក្រឡទែន ស្អូច** - ស៊េរីថ្នាំចាក់ដើម្បីបង្ការកុំឱ្យកុមារឆ្លងជំងឺធ្ងន់ធ្ងរដែលអាចបង្កជាជំងឺត្រចៀក រលាកសួត ខូចខួរក្បាល និងខូចទ្រង់ទ្រាយទារកក្នុងផ្ទៃស្ត្រីមានផ្ទៃពោះ។

**អុតស្វាយ** - ថ្នាំចាក់ដើម្បីបង្ការកុំឱ្យកុមារឆ្លងជំងឺអុតស្វាយ។ កុមារមួយចំនួនអាចកើតជំងឺរលាកសួតដោយសារជំងឺនេះ។

**ជំងឺរលាកថ្លើមប្រភេទ A** - ស៊េរីថ្នាំចាក់ដើម្បីបង្ការកុំឱ្យកុមារឆ្លងជំងឺថ្លើមធ្ងន់ធ្ងរដែលអាចបណ្តាលឱ្យភ្នែក ឬស្បែកមានពណ៌លឿង (ខាន់លឿង) ឈឺក្រពះធ្ងន់ធ្ងរ និងរាករូស។

**វីរុសដុះសាច់លើខ្លួនមនុស្ស (HPV)** - ស៊េរីថ្នាំចាក់ដើម្បីបង្ការកុំឱ្យដុះឬសលើប្រដាប់ភេទ និងប្រភេទជាក់លាក់នៃជំងឺមហារីក។ មានប្រសិទ្ធភាពបំផុតនៅពេលចាក់ក្នុងវ័យជាកុមារ។

**ការពិនិត្យរកសារធាតុសំណក្នុងឈាម** - ការធ្វើតេស្តឈាមដែលធ្វើឡើងនៅអាយុ 12 ខែ និង 2 ឆ្នាំ ដោយមានការធ្វើតេស្តបង្គ្រប់នៅអាយុ 3-5 ឆ្នាំ ប្រសិនបើមិនបានធ្វើតេស្តលើកដំបូងទេ។ នេះជាការធ្វើតេស្តរកមើលកម្រិតសារធាតុសំណខ្ពស់ក្នុងខ្លួនកុមារ ដែលអាចបណ្តាលឱ្យឈឺក្រពះ ឈឺក្បាល បញ្ហារៀនសូត្រ និងប្រកាច់។

**ជំងឺរបេង (TB)** - ស៊េរីនៃការពិនិត្យដើម្បីវាយតម្លៃហានិភ័យដែលអាចកើតជំងឺ TB។ របេងគឺជាជំងឺបង្កដោយបាក់តេរីដែលអាចវាយប្រហារសួត តម្រងនោម ឆ្អឹងខ្នង និងខួរក្បាល។ ប្រសិនបើកូនរបស់អ្នកមានហានិភ័យដែលអាចកើតជំងឺ TB នោះអាចនឹងត្រូវធ្វើតេស្តឈាមឬស្បែកដើម្បីរកមើល។

**ជំងឺខ្វះជាតិខ្លាញ់** - ស៊េរីនៃការពិនិត្យរកសារជាតិខ្លាញ់ (លីពីត) ក្នុងឈាម ដោយធ្វើតេស្តឈាមនៅចន្លោះអាយុ 9-11 ឆ្នាំ ដើម្បីរកមើលខ្លាញ់មិនមានតុល្យភាព ឬមានបរិមាណខ្ពស់។

**ជំងឺស្លេកស្លាំង** - ស៊េរីនៃការពិនិត្យ ដោយធ្វើតេស្តឈាមនៅអាយុ 12 ខែ ដើម្បីវាយតម្លៃហានិភ័យដែលអាចមានចំនួនកោសិកាឈាមទាប។ វាអាចបណ្តាលឱ្យខ្វះអុកស៊ីសែន និងអាចធ្វើឱ្យអ្នកមានអារម្មណ៍ថាហត់ ឬខ្សោយ។

**ការពិនិត្យវិសាលភាពជំងឺអូទីហ្សឹម (ASD)** - ការពិនិត្យដែលធ្វើឡើងដើម្បីធ្វើតេស្តរក ASD ជាពិការភាពបង្អាក់ការលូតលាស់ដែលបណ្តាលមកពីភាពខុសគ្នានៃខួរក្បាល។ កុមារដែលមានជំងឺ ASD ជាធម្មតាមានបញ្ហាក្នុងការប្រាស្រ័យទាក់ទងគ្នា ហើយក៏អាចមានវិធីខុសគ្នាក្នុងការសិក្សា ផ្លាស់ទី ឬផ្តង់អារម្មណ៍ផងដែរ។

**ការពិនិត្យជំងឺធ្លាក់ទឹកចិត្តរបស់ម្តាយ** - ការពិនិត្យដែលធ្វើឡើងដើម្បីរកមើលជំងឺធ្លាក់ទឹកចិត្ត ដែលអាចកើតឡើងក្រោយពេលបង្កើតកូនរួច។ រួមបញ្ចូលបញ្ហាសុខភាពជាច្រើនដែលអាចប៉ះពាល់ដល់ស្ត្រីអំឡុងពេលមានផ្ទៃពោះ និងក្រោយបង្កើតកូនរួចរហូតដល់មួយឆ្នាំ។

**ការពិនិត្យការលូតលាស់** - ការពិនិត្យដែលធ្វើឡើងនៅដំណាក់កាលជាច្រើននៃការលូតលាស់ ដើម្បីប្រាកដថាកូនរបស់អ្នកកំពុងលូតលាស់ប្រកបដោយសុខភាពល្អ។

**ការពិនិត្យជំងឺរលាកថ្លើមប្រភេទ B** - ការពិនិត្យដើម្បីវាយតម្លៃហានិភ័យដែលអាចកើតជំងឺរលាកថ្លើមប្រភេទ B ត្រូវធ្វើឡើងនៅពេលពិនិត្យសុខុមាលភាពមួយលើកៗពីថ្ងៃកើតរហូតដល់អាយុ 20 ឆ្នាំ។ ជំងឺនេះអាចបណ្តាលឱ្យខូចថ្លើម មហារីកថ្លើម ឬស្លាប់បាន។

**ថ្នាំលាបមានសារជាតិភ្លុយអរ** - ចាប់ពីអាយុ 6 ខែ ឬនៅពេលដុះពន្លកធ្មេញដំបូង ថ្នាំលាបមានសារជាតិភ្លុយអរត្រូវបានប្រើលើធ្មេញរបស់កុមារ។ ថ្នាំលាបមានសារជាតិភ្លុយអរគឺជាថ្នាំទន្តសាស្ត្រដែលអាចបង្ការកុំឱ្យពុកធ្មេញ ពន្យឺតភាពពុក ឬរារាំងកុំឱ្យកាន់តែធ្ងន់ធ្ងរ។

**សុខភាពមាត់** - ការប្រើភ្នែកពិនិត្យមាត់ត្រូវបានធ្វើឡើងក្នុងអំឡុងពេលទៅជួបគ្រូពេទ្យពិនិត្យសុខុមាលភាពកុមារ ដើម្បីប្រាកដថាមាត់ធ្មេញមានសុខភាពល្អ និងលូតលាស់បានត្រឹមត្រូវ។ ប្រសិនបើកុមារមិនទៅជួបពេទ្យធ្មេញនៅអាយុ 12 ខែទេ គ្រូពេទ្យគួរតែណែនាំឱ្យទៅពេទ្យធ្មេញ ដើម្បីពិនិត្យធ្មេញជាប្រចាំ។

**ការពិនិត្យភាពមិនប្រក្រតីនៃការបរិភោគ** - ការពិនិត្យដែលត្រូវធ្វើឡើងនៅអាយុចន្លោះពី 10 ទៅ 20 ឆ្នាំ ដើម្បីរកមើលបញ្ហាបរិភោគមិនប្រក្រតី។ បញ្ហាទាំងនេះអាចបង្កគ្រោះថ្នាក់ដល់ជីវិត និងអាចស្លាប់ទៀតផង។

**ការពិនិត្យសុខុមាលភាពកុមារ** - កូនរបស់អ្នកនឹងទៅជួបគ្រូពេទ្យជាទៀងទាត់ ដើម្បីពិនិត្យសុខភាពឱ្យប្រាកដថាគាត់បន្តមានសុខភាពល្អ។ គ្រូពេទ្យរបស់កូនអ្នកនឹងពិគ្រោះជាមួយអ្នកអំពីសុខភាពរបស់កូនអ្នក រាល់ក្តីកង្វល់ដែលអ្នកមាន និងពិនិត្យកូនរបស់អ្នក។ គាត់ក៏នឹងពិនិត្យព័ត៌មានសុខភាព និងសុវត្ថិភាពសំខាន់ៗជាមួយអ្នកអំពីអ្វីដែលត្រូវរំពឹងទុក ខណៈពេលដែលកូនរបស់អ្នកលូតលាស់។



# គោលការណ៍ណែនាំស្តីពីការលូតលាស់និងរក្សាសុខភាពល្អ

(ពីថ្ងៃកំណើតដល់ 10 ឆ្នាំ)

MolinaHealthcare.com

32120BROMDCAKM
231207

ដើម្បីទទួលបានព័ត៌មាននេះជាភាសាដែលអ្នកចង់ប្រើ និងទម្រង់ងាយស្រួលមើល សូមហៅទូរសព្ទទៅសេវាសម្រាប់សមាជិក។ លេខទូរសព្ទមាននៅផ្នែកខាងក្រោយនៃកាតសម្គាល់ខ្លួនរបស់អ្នក។

# គោលការណ៍ណែនាំស្ដីពីការលូតលាស់ និងរក្សាសុខភាពល្អ (ពីថ្ងៃកើតដល់ 10 ឆ្នាំ)

ការចិញ្ចឹមកូនអាចមានកិច្ចការច្រើនត្រូវធ្វើ! ការដឹងថាពេលណាត្រូវនាំគាត់ទៅជួបគ្រូពេទ្យអាចមានការភាន់ច្រឡំបន្តិច។ អនុវត្តតាមការណែនាំនេះដើម្បីជួយកូនរបស់អ្នកលូតលាស់ដោយមានសុខភាពល្អ!



| | ពេលកើត | 1 ខែ | 2 ខែ | 4 ខែ | 6 ខែ | 9 ខែ | 12 ខែ | 15 ខែ | 18 ខែ | 2 ឆ្នាំ | 30 ខែ | 3 ឆ្នាំ | 4 ឆ្នាំ | 5 ឆ្នាំ | 6 ឆ្នាំ | 7-10 ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B | ដូសទី 1 | ដូសទី 2 | | | ដូសទី 3 | | | | | | | | | | | |
| វីរុសធ្វើឱ្យកុមាររាករូស | | | ដូសទី 1 | ដូសទី 2 | ដូសទី 3 (បើជាស៊េរីមាន 3 ដូស) | | | | | | | | | | | |
| ខាន់ស្លាក់ តេតាណូស ក្អកមាន់ (DTap) | | | ដូសទី 1 | ដូសទី 2 | ដូសទី 3 | | | ដូសទី 4 | | | | | ដូសទី 5 | | | |
| ញូម៉ូខូខល | | | ដូសទី 1 | ដូសទី 2 | ដូសទី 3 | | ដូសទី 4 (បើជាស៊េរីមាន 4 ដូស) | | | | | | | | | |
| វ៉ាក់សាំងប៉ូល្យូអសកម្ម | | | ដូសទី 1 | ដូសទី 2 | ដូសទី 3 | | | | | | | | ដូសទី 4 | | | |
| ផ្តាសាយធំហេម៉ូហ្វីលីសប្រភេទ B | | | ដូសទី 1 | ដូសទី 2 | ដូសទី 3 | | ដូសទី 4 (បើជាស៊េរីមាន 4 ដូស) | | | | | | | | | |
| ផ្តាសាយធំ | | | | | វ៉ាក់សាំងផ្តាសាយធំ - រៀងរាល់ឆ្នាំ (ចាប់ពីអាយុ 6 ខែ) - រដូវមានជំងឺផ្តាសាយធំ | | | | | | | | | | | |
| កញ្ជ្រឹល ក្រឡទែន ស្អូច | | | | | | | ដូសទី 1 | | | | | | ដូសទី 2 | | | |
| អុតស្វាយ | | | | | | | ដូសទី 1 | | | | | | ដូសទី 2 | | | |
| ជំងឺរលាកថ្លើមប្រភេទ A | | | | | | | ដូសទី 1 | | ដូសទី 2 | | | | | | | |
| វីរុសដុះសាច់លើខ្លួនមនុស្ស (HPV) | | | | | | | | | | | | | | | | ដូសទី 1 (9-10 ឆ្នាំ) |
| ការពិនិត្យរកសារធាតុសំណក្នុងឈាម | | | | | | | ធ្វើតេស្ត | | | ធ្វើតេស្ត | | ធ្វើតេស្តបង្គ្រប់ | | | | |
| ជំងឺរបេង | | | | | | | | | | | | ម្តងក្នុងពេលពិនិត្យសុខុមាលភាពមួយលើក | | | | |
| ជំងឺខ្វះជាតិខ្លាញ់ | | | | | | | | | | ការពិនិត្យ | | | ការពិនិត្យ | | ការពិនិត្យ | ធ្វើតេស្តចន្លោះ 9-11 ឆ្នាំ |
| ជំងឺស្លេកស្លាំង | | | | ការពិនិត្យ | | | ធ្វើតេស្ត | ការពិនិត្យម្តងរៀងរាល់ពេលពិនិត្យសុខភាព | | | | | | | | |
| ការពិនិត្យវិសាលភាពជំងឺអូទីហ្ស៊ឹម | | | | | | | | | | | | | | | | |
| ការពិនិត្យជំងឺធ្លាក់ទឹកចិត្តរបស់ម្តាយ | | | | | | | | | | | | | | | | |
| ការពិនិត្យការលូតលាស់ | | | | | |  | | |  | |  | | | | | |
| ការពិនិត្យជំងឺរលាកថ្លើមប្រភេទ B | ការពិនិត្យម្តងរៀងរាល់ពេលពិនិត្យសុខភាព | | | | | | | | | | | | | | | |
| ការពិនិត្យភាពមិនប្រក្រតីនៃការបរិភោគ | | | | | | | | | | | | | | | | ការពិនិត្យនៅអាយុ 10 ឆ្នាំ |
| ការពិនិត្យសុខុមាលភាពកុមារ | | | | | | | | | | | | | | | | |
| ថ្នាំលាបមានសារជាតិភ្លុយអរ | | | | | រៀងរាល់ 3-6 ខែម្តង | | | | | | | | | | | |
| សុខភាពមាត់ | | | | | ជួបគ្រូពេទ្យជាទៀងទាត់ | | | | | | | | | | | |

តើអ្នកមានសំណួរឬ? សូមហៅទៅខ្សែទូរសព្ទផ្តល់ដំបូន្មានអំពីការមើលថែ 24 ម៉ោងរបស់យើង៖ អង់គ្លេស៖ (888) 275-8750 | ខ្មែរ (866) 648-3537 | TTY (អង់គ្លេស និងខ្មែរ) 711